# ព្រះរាជក្រឹត្យ

នស/រកត/០៦២០/៦៦១

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាអ្នកច្បាប់

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានបង្កើតក្រុមប្រឹក្សាអ្នកច្បាប់ដែលសរសេរជាអក្សរកាត់ថា **ក.ប.ច.** ជាអង្គភាពអមទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងការសម្របសម្រួលការងារតាក់តែង និងក្នុងការពិនិត្យផ្តល់យោបល់ លើសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជូនរាជរដ្ឋាភិបាល។

ROYAUME DU CAMBODGE * LE MINISTERE DU PALAIS ROYAL *

## ជំពូកទី២
## តួនាទីនិងភារកិច្ចរបស់ ក.ប.ច.

**មាត្រា២ .-**

**ក.ប.ច.**មានតួនាទីនិងភារកិច្ចដូចតទៅ៖

- សិក្សាស្រាវជ្រាវ ពិនិត្យ និងផ្ដល់យោបល់លើសេចក្ដីព្រាងច្បាប់ លិខិតបទដ្ឋានគតិយុត្តផ្សេងទៀត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព សន្ធិសញ្ញា អនុសញ្ញា និងកិច្ចព្រមព្រៀងនានា ដែលបណ្ដាក្រសួង ស្ថាប័នពាក់ព័ន្ធស្នើសុំការសម្រេចពីរាជរដ្ឋាភិបាល
- សិក្សានិងពិនិត្យលើច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតដែលមិនសមស្របនឹងវឌ្ឍនភាពសង្គម ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីលើកយោបល់ជូនរាជរដ្ឋាភិបាលធ្វើវិសោធនកម្មឬកែសម្រួល
- សិក្សាស្រាវជ្រាវ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីសម្របសម្រួលក្នុងការរៀបចំសេចក្ដីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតដែលចាំបាច់សម្រាប់បម្រើឱ្យគោលនយោបាយរបស់រាជរដ្ឋាភិបាល
- ធ្វើទំនាក់ទំនងជាមួយនឹងអង្គការជាតិ អង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍនានា ដើម្បីសិក្សាស្វែងយល់ ផ្លាស់ប្ដូរបទពិសោធន៍ និងធ្វើសហប្រតិបត្តិការការងារ
- សម្របសម្រួលក្នុងការរៀបចំលិខិតឆ្លើយតបឬសេចក្ដីបំភ្លឺរបស់រាជរដ្ឋាភិបាលចំពោះសំណួររបស់រដ្ឋសភា
- រៀបចំបែបបទបញ្ជូនសេចក្ដីព្រាងច្បាប់ដែលទទួលបានការសម្រេចឯកភាពឬយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីស្នើសុំការពិនិត្យនិងអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិ
- សម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការពិនិត្យនិងផ្ដល់យោបល់ចំពោះអនុសាសន៍របស់រាជរដ្ឋាភិបាលលើសេចក្ដីស្នើច្បាប់តាមសំណើរបស់ស្ថាប័ននីតិប្បញ្ញត្តិ
- សម្របសម្រួលការរៀបចំសមាសភាពតំណាងរាជរដ្ឋាភិបាលទៅការពារសេចក្ដីព្រាងច្បាប់ឬទៅបំភ្លឺនៅស្ថាប័ននីតិប្បញ្ញត្តិ
- រៀបចំបែបបទជូននាយករដ្ឋមន្ត្រីដើម្បីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រសូមឡាយព្រះហស្តលេខាលើព្រះរាជក្រមប្រកាសឱ្យប្រើច្បាប់ដែលទទួលបានការអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិ
- រៀបចំបែបបទជូននាយករដ្ឋមន្ត្រីដើម្បីចុះហត្ថលេខាលើលិខិតបទដ្ឋានគតិយុត្ត ឬដើម្បីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រសូមឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យ តាមការប្រគល់ពីរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី
- ផ្ដល់យោបល់និងសម្របសម្រួលវិវាទរដ្ឋបាលនានាតាមការប្រគល់ពីប្រមុខរាជរដ្ឋាភិបាល
- ស្រាវជ្រាវនិងផ្សព្វផ្សាយច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត
- ធ្វើរបាយការណ៍ស្ដីអំពីសកម្មភាពការងាររបស់ **ក.ប.ច.** ជូនប្រមុខរាជរដ្ឋាភិបាល
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីប្រមុខរាជរដ្ឋាភិបាល។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

## ជំពូកទី៣
## សមាសភាពរបស់ ក.ប.ច.

**មាត្រា៣ .-**

**ក.ប.ច.** ស្ថិតក្រោមការគ្រប់គ្រងនិងដឹកនាំផ្ទាល់របស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីជាប្រធាន ដោយមានអនុប្រធាន និងសមាជិក សម្រាប់ជួយបំពេញការងារ។

ប្រធាន អនុប្រធាន និងសមាជិករបស់ **ក.ប.ច.** ត្រូវតែងតាំងនិងបញ្ចប់មុខតំណែងដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី។

**មាត្រា៤ .-**

បុគ្គលដែលអាចត្រូវបានជ្រើសតាំងឱ្យបំពេញមុខងារជាសមាជិកនៃ **ក.ប.ច.** ត្រូវមានលក្ខខណ្ឌទាំង៤(បួន) ដូចខាងក្រោម៖

- សញ្ញាបត្រចាប់ពីបរិញ្ញាបត្រនីតិសាស្ត្រជាមូលដ្ឋានឡើងទៅ
- បទពិសោធន៍ការងារក្នុងឬក្រៅប្រទេសយ៉ាងតិច៥(ប្រាំ)ឆ្នាំលើមុខជំនាញនីតិសាស្ត្រឬជំនាញដទៃទៀត
- ចំណេះដឹងទូលំទូលាយនិងមានសីលធម៌ល្អ
- មិនធ្លាប់ត្រូវបានផ្តន្ទាទោសពីបទមជ្ឈិមឬបទឧក្រិដ្ឋណាមួយ។

## ជំពូកទី៤
## គណៈប្រតិបត្តិរបស់ ក.ប.ច.

**មាត្រា៥ .-**

**ក.ប.ច.** មានគណៈប្រតិបត្តិមួយសម្រាប់សម្របសម្រួលការងារប្រចាំថ្ងៃរបស់ **ក.ប.ច.** ។

គណៈប្រតិបត្តិ **ក.ប.ច.** មានអនុប្រធាន **ក.ប.ច.** ជាប្រធាន និងមានអនុប្រធាន **ក.ប.ច.** និងអគ្គលេខាធិការ ជាសមាជិក។

របៀបរបបការងារនិងកិច្ចដំណើរការប្រជុំរបស់គណៈប្រតិបត្តិ **ក.ប.ច.** ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់ **ក.ប.ច.** ។

សមាសភាពជាក់ស្តែងនៃគណៈប្រតិបត្តិ **ក.ប.ច.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **ក.ប.ច.**។

**មាត្រា៦ .-**

ក្រោមការដឹកនាំនិងបញ្ជាផ្ទាល់របស់ប្រធាន **ក.ប.ច.** គណៈប្រតិបត្តិ **ក.ប.ច.** មានភារកិច្ចដូចខាងក្រោម៖

- កំណត់របៀបវារៈកិច្ចប្រជុំនានារបស់ **ក.ប.ច.**
- កោះអញ្ជើញសមាជិកចូលរាយការណ៍និងធ្វើរបាយការណ៍ស្តីពីកិច្ចប្រជុំនានា
- ផ្តល់អនុសាសន៍និងមតិណែនាំដល់ក្រុមការងារនីមួយៗរបស់ **ក.ប.ច.**

- ពិនិត្យនិងតម្រង់ទិសលើមតិដែលមិនឯកភាពគ្នារវាងក្រុមការងារ **ក.ប.ច.** ឬរវាងក្រុមការងារ **ក.ប.ច.** និងក្រសួង ស្ថាប័នពាក់ព័ន្ធនានា
- ពិនិត្យនិងវាយតម្លៃលើការងាររបស់សមាជិក **ក.ប.ច.** ដើម្បីស្នើសុំគ្រឿងឥស្សរិយយសឬដំឡើងឋានៈ ថ្នាក់ និងឋានន្តរសក្តិ
- ពិនិត្យលើកំហុសរបស់អនុប្រធានឬសមាជិក **ក.ប.ច.** ដើម្បីលើកសំណើជូនប្រធាន **ក.ប.ច.** ពិនិត្យនិងសម្រេចដាក់ទណ្ឌកម្មខាងវិន័យ។ លក្ខខណ្ឌទណ្ឌកម្មខាងវិន័យ ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់ **ក.ប.ច.**។

## ជំពូកទី៥
## ការប្រព្រឹត្តទៅរបស់ ក.ប.ច.

**មាត្រា៧ ._**

ប្រធាន **ក.ប.ច.** ដឹកនាំកិច្ចការទូទៅរបស់ **ក.ប.ច.**។ ប្រធានអាចប្រគល់សិទ្ធិជូនអនុប្រធានណាម្នាក់ដើម្បីដឹកនាំការងារប្រចាំថ្ងៃជំនួស។

នៅពេលដែលប្រធាន **ក.ប.ច.** អវត្តមានឬមានករណីចាំបាច់ ប្រធាន **ក.ប.ច.** អាចប្រគល់សិទ្ធិជូនអនុប្រធាន **ក.ប.ច.** ណាម្នាក់ឱ្យទទួលដឹកនាំការងារប្រចាំថ្ងៃរបស់ **ក.ប.ច.** ក្នុងឋានៈជាប្រធានស្តីទីរហូតដល់មានវត្តមានប្រធាន **ក.ប.ច.**។

អនុប្រធាន **ក.ប.ច.** អនុវត្តការងារតាមការកំណត់របស់ប្រធាន ដូចមានចែងក្នុងសេចក្តីសម្រេចស្តីពីការបែងចែកភារកិច្ច។

**មាត្រា៨ ._**

ក្នុងការបំពេញការងារ **ក.ប.ច.** ត្រូវបែងចែកជាក្រុមការងារ។ ក្រុមការងារនីមួយៗត្រូវដឹកនាំដោយប្រធាន១(មួយ)រូប និងអនុប្រធានមួយចំនួនតាមការចាំបាច់។

ចំនួនក្រុមការងារនិងចំនួនសមាជិកនៃក្រុមការងារនីមួយៗ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **ក.ប.ច.**។

**ក.ប.ច.** ប្រជុំសាមញ្ញយ៉ាងតិច២(ពីរ)ដងក្នុងមួយឆ្នាំ។ ក្នុងករណីចាំបាច់ **ក.ប.ច.** អាចប្រជុំជាវិសាមញ្ញតាមការកោះអញ្ជើញរបស់ប្រធាន **ក.ប.ច.** ។

របៀបរបបការងារនិងកិច្ចដំណើរការប្រជុំរបស់ **ក.ប.ច.** ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់ **ក.ប.ច.**។

**មាត្រា៩ ._**

**ក.ប.ច.** អាចអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ មន្ត្រីជំនាញ ចូលរួមប្រជុំពិគ្រោះយោបល់និងបំភ្លឺលើរាល់បញ្ហាទាំងឡាយដែលពាក់ព័ន្ធនឹងក្របខ័ណ្ឌការងាររបស់ខ្លួន។

ដើម្បីបំពេញការងារប្រកបដោយប្រសិទ្ធភាពជូនរាជរដ្ឋាភិបាល **ក.ប.ច.** អាចតម្រូវឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធ ផ្តល់ឯកសារ ទិន្នន័យ និងព័ត៌មាននានា ដែលទាក់ទងនឹងការកសាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជូន **ក.ប.ច.** ផង។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**មាត្រា១០ .-**

**គ.ប.ច**. អាចមានទីប្រឹក្សានិងជំនួយការមួយចំនួនតាមការចាំបាច់។

ទីប្រឹក្សានិងជំនួយការ **គ.ប.ច**. ត្រូវតែងតាំងដោយព្រះរាជក្រឹត្យឬអនុក្រឹត្យ។

**មាត្រា១១ .-**

**គ.ប.ច**. ត្រូវមានតំណាងចូលរួមប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីនិងកិច្ចប្រជុំនានាដែលរៀបចំឡើងដោយទីស្តីការគណៈរដ្ឋមន្ត្រី។

**មាត្រា១២ .-**

**គ.ប.ច**. មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការសម្រាប់ដំណើរការការងារប្រចាំថ្ងៃ។

អគ្គលេខាធិការដ្ឋាន **គ.ប.ច**. ដឹកនាំដោយអគ្គលេខាធិការ១(មួយ)រូបនិងមានអគ្គលេខាធិការរងមួយចំនួនតាមការចាំបាច់ ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

អគ្គលេខាធិការនិងអគ្គលេខាធិការរង **គ.ប.ច**. ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន **គ.ប.ច**. ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា១៣ .-**

**គ.ប.ច**. មានសិទ្ធិប្រើត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីដំណើរការការងារប្រចាំថ្ងៃរបស់ខ្លួន។

**មាត្រា១៤ .-**

ប្រាក់បំណាច់មុខងារនិងអត្ថប្រយោជន៍ផ្សេងៗទៀតរបស់ប្រធាន អនុប្រធាន សមាជិក ទីប្រឹក្សា ជំនួយការ និងមន្ត្រីអគ្គលេខាធិការដ្ឋាន **គ.ប.ច**. ត្រូវកំណត់ដោយរាជរដ្ឋាភិបាល។

## ជំពូកទី៦
## ប្រភពធនធានរបស់ គ.ប.ច.

**មាត្រា១៥ .-**

**គ.ប.ច**. មានប្រភពធនធានផ្គត់ផ្គង់ដោយថវិកាជាតិជាកញ្ចប់ថវិកាដោយឡែក នៅក្នុងក្របខ័ណ្ឌថវិកាប្រចាំឆ្នាំរបស់ទីស្តីការគណៈរដ្ឋមន្ត្រី។

**គ.ប.ច**. មានសិទ្ធិទទួលនិងចាត់ចែងប្រើប្រាស់តាមនីតិវិធីដូចមានកំណត់ក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាននូវមូលនិធិដែលបានមកពីដៃគូអភិវឌ្ឍនិងប្រភពស្របច្បាប់ផ្សេងៗទៀត សម្រាប់ដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៧
## អន្តរប្បញ្ញត្តិ

**មាត្រា១៦ .-**

លិខិតបទដ្ឋានគតិយុត្តទាំងឡាយដែលពាក់ព័ន្ធនឹងការតែងតាំងប្រធាន អនុប្រធាន សមាជិក ទីប្រឹក្សា និងមន្ត្រីរាជការអគ្គលេខាធិការដ្ឋាន **គ.ប.ច**. ព្រមទាំងរចនាសម្ព័ន្ធរបស់ **គ.ប.ច**. ត្រូវមានអានុភាពអនុវត្តបន្តទៅទៀតរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសស្របតាមបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ។

## ជំពូកទី៨
## អវសានប្បញ្ញត្តិ

**មាត្រា១៧ .-**

អនុក្រឹត្យលេខ៣២ អនក្រ.បក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការបង្កើតក្រុមប្រឹក្សាអ្នកច្បាប់ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៨ .-**

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ថ្ងៃ ពុធ ៤កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ២០២០

នស/រកត/០៦២០/៦៧៩

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**